ម៉ាលីយ៉ា អង្គុយនៅលើកៅអីទោលដោយហើបជើងម្តងៗស្ទើរហោះហើរដូចកំពុងស្ថិតក្នុងយានលើមេឃ។ តាមពិតនេះ ជាបន្ទប់សណ្ឋាគារ.....នាងដឹង.....តែ.....ហ៊ឹម ពន្លឺពីចង្កៀងចរណៃពណ៌មាស បញ្ចាំងមកលើស្រទាប់ផែនថ្ពាលើនាងទន់ៗ ប៉ុន្តែភ្នែកនាងមើលមិនច្បាស់ ម្តងបើកម្តងបិទ។

គ្រប់យ៉ាងសន្ទិយានិងស្ងប់ស្ងាត់ តែបេះដូងនាងមិនមានសន្តិភាពនោះទេ។ កែវស្រាក្រហមនៅចន្លោះម្រាមដៃនាង នៅតែក្រឡុកនិងភ្លឺចែងចាំង។

តែ.....ស្រីមិនអាចស្មានឱ្យដឹងច្បាស់នូវអារម្មណ៍ខ្លួនឯងបានឡើយ។

សំណើចនៃពិធីជប់លៀងនៅខាងក្រៅបន្ទប់ រសាត់ទៅឆ្ងាយបន្តិចៗម្តងៗទៅតាមក្បាលនាងដែលក្តៅ និងធ្ងន់។ ចាំបានថា ខាងក្រោមជាបទភ្លេងកំដរកម្មវិធីរាំរែក សម្រាប់ពីពិធីជប់លៀងមួយរបស់បងប្រុសនាង។ ហេតុអ្វីនាងឡើងមកដល់ទីនេះ? ក្នុងបន្ទប់ស្ងប់ៗ ប៉ុន្តែបេះដូងនាងវាយលឿនដូចស្គរ?

ដូចជាអារម្មណ៍មួយ....កំពុងចូលបញ្ជាលើកាយសម្បទារបស់នាង។ ជាមួយនោះ....នាងស្រាប់តែឃើញគេ.....មនុស្សម្នាក់.....ក្រអឺតក្រទម មិនដែលត្រូវរ៉ូវជាមួយនាង។

ហ្សាងជីន បុរសដើមកំណើតសិង្ហបុរីដែលបច្ចុប្បន្នរស់នៅអាមេរិក គេដើរចូលមកក្នុងបន្ទប់នេះធ្វើស្អី? គេមានកាយសម្បទារឹងមាំ សក់ហ៊ីហា និងភ្នែកឆ្មើងកន្ទ្រើងដូចលោកនេះមានតែគេម្នាក់ប៉ុណ្ណោះជាសហគ្រិនឆ្លាតវៃ..... ប៉ុន្តែ....ភាពគួរឱ្យជិនទាំងអស់របស់គេ ម្តេចប្រែក្លាយមកជាភាពស្រស់ស្អាតបាន? ហើយ....បង្កើនអារម្មណ៍ក្តៅៗចម្លែកម្យ៉ាងនៅចិត្តក្នុងម៉ាលីយ៉ា។

ហ្សាងជីនភ្ញាក់ ពេលឃើញនាង។

ម៉ាលីយ៉ា...?

ហើយនេះឯង ការចាប់ផ្តើមរវាងពួកគេ។

## ជំពូកទីមួយ

### អតីតCrush

ហ្យាងជី ជាមិត្តជិតដិតបំផុតរបស់បងប្រុសខ្ញុំ តែប៉ុហ្នឹងតែងតែជាសត្រូវរបស់ខ្ញុំ។ ឥឡូវនេះ គេត្រូវក្លាយមកជាប្ដីរបស់ខ្ញុំ????? អរគុណច្រើន ឡាសវេហ្គាស!

សម្រាប់ខ្ញុំ ហ្យាងជីស្មីនេះ គឺជាមនុស្សដែលរំខានចិត្តបំផុតនៅលើភពផែនដី។

និយាយពីមនុស្សប្រុស ខ្ញុំធ្លាប់មានស្នេហាដំបូងនិងការណាត់ជួបពីរដង តែទំនាក់ទំនងមិនដែលល្អទេ។ មកពីគ្រួសារខ្ញុំជាខ្មែរដែលមានមុខមាត់នៅទីនេះ បានជាខ្ញុំជួបសុទ្ធតែប្រុសតោងស៊ី។

ខ្ញុំធ្លាប់ឈឺ ហើយបានស្បថថា ជាតិនេះខ្ជិលរៀបការណាស់។

ប៉ុន្តែ.....យប់នោះ.....ខ្ញុំត្រូវបានគេចងដោយផ្លូវច្បាប់ ទៅនឹងមនុស្សម្នាក់ដែលគួរឱ្យធុញជាងគេក្នុងលោក.....លេងសើចណាស់លោកព្រហ្មលិខិត។

នឹកឃើញពីការចាប់ផ្ដើមរវាងយើង.....នៅលើទឹកដីឡាសវេហ្គាស ដែលរមែងត្រូវបានគេឯងសន្មតថា នេះជាទឹកដីនៃភ័ព្វសំណាង។

ខ្ញុំអុកកែងដៃសំដៅឆ្អឹងជំនីប្អូនស្រីខ្ញុំតិចៗ គឺម៉ាលីដា ហៅក្រៅលីដេ។

ស្នាមញញឹមនៅលើមុខរបស់លីដាប្រាប់ខ្ញុំស្រេចថា កែងដៃខ្ញុំប៉ះ ប៉ុន្តែនាងមិនឈឺទេ នាងដឹងទៀតខ្ញុំអៀននឹងប្រុសស្អាតៗ សេដ្ឋីៗជាច្រើន....។

ខ្ញុំខ្សឹបខ្សៀបជាភាសាខ្មែរ៖

«ហេ៎ ម៉េចបានប៉ិតុនមកដែរ?»

លីដេក្រឡេកមើលទៅកាន់បងប្រុសធំសេដ្ឋីវាល់លានរបស់ពួកយើង គាត់ឈ្មោះខ្មែរថា ម៉ារៈ តែនៅទីនេះ គេហៅគាត់ថា ម៉ីក។

បងម៉ីកនៅក្បែរតុបៀរក្នុងកាស៊ីណូដែលមានអភិជនជាច្រើនជុំគ្នាយ៉ាងគឃ្លើន។ រំពេចនោះខ្ញុំឃើញប៉ុម្នាក់ដែលអង្គុយនៅខាងឆ្វេងបងម៉ីកគឺ.....អ្ហឹយ....កំពូលមិត្តល្អបំផុតរបស់បងធំខ្ញុំ គេនោះជ្រិញ! ជាចិនសាំងហ្គាពួរឈ្មោះ ហ្យាងជី ហៅថា Ton (តុន)។

ខ្ញុំបានស្គាល់មនុស្សនេះយូរហើយ យូរណាស់ តាមដែលខ្ញុំអាចចាំបានហើយជាច្រើនលើក អនុស្សាវរីយ៍រវាងយើងមានតែ ដើរចេញបោកកែវ ឬស្ទុះទៅរកចង់ច្របាច់កគ្នា។

លីដេញញឹមៈ

«គេជាដៃគូរកស៊ី ល្អបំផុតរបស់ បងមីក អត់អញ្ជើញកើតដែរ?»

ខ្ញុំវែកសក់ពីរបីសរសៃដែលស្រោប់តែធ្ងន់រំខានទៅនៅខាងក្រោយត្រចៀក។ មិនមែនសក់សូត្រនេះចេះរំខានខ្ញុំទេ តែប្រុសម្នាក់ហ្នឹង.....ហើយងើបមុខមកមើលខ្ញុំទៀត មិនដែលឃើញស្រីស្អាតទេ? ខ្ញុំធ្វើពើយ ងាកចេញមើលអ្នកផ្សេងៗវិញ។

តាមការក្រឡេកនោះ ខ្ញុំមើលទៅឃើញនារីម្នាក់ទៀត ទំនងព័រទុយហ្គាល់ឬមួយអាចជាជនជាតិមិកសិក នាងមានសម្រស់ស្រស់ស្អាតជាខ្លាំង ដោយស្លៀករ៉ូបវែងពណ៌ស ហក់លោតពត់ពេនចុះឡើងលើកកែវស្រា នៅជាប់នឹងនាងគឺបុរសអាមេរិកម្នាក់ស្លៀកឈុតមានតម្លៃពណ៌ខ្មៅ ពាក់ក្រវ៉ាត់កពណ៌ក្រហម។

«តើទៅវិហាររៀបការ?» លីដេខ្សឹប ដៃក៏លូកប៉ះទ្រូងព្រោះប្អូនខ្ញុំហួសចិត្ត។ លីដេ អាយុតិចជាងខ្ញុំបីឆ្នាំតែបានរៀបការយ៉ាងសប្បាយចិត្តជាមួយតូរី ជាបុរសដែលលីដេស្រលាញ់ រហូតដល់ពេលនេះ អ្នកទាំងពីរមានកូនស្រីដ៏ស្រស់ស្អាតម្នាក់។

ជាធម្មជាតិលីដេជានារីខ្មែរទាន់សម័យម្នាក់មានការជឿជាក់លើស្នេហាពិត។ ប្អូនខ្ញុំបានរកឃើញស្នេហាប្រភេទនេះ តាមរយៈប្ដីរបស់នាង។ ចំណែកថ្មីៗនេះទៀត បងមីករបស់ពួកយើង ក៏ជិតរៀបការជាមួយនឹងមនុស្សស្រីជាទីស្រលាញ់ក្នុងជីវិតគេដែរ។

ចុងក្រោយទៅ ខ្ញុំជាមនុស្សឯកោដែលគ្រប់គ្នាក្នុងផ្ទះផ្ដោតភ្នែកសួររកចម្លើយ។ ថ្ងៃណាៗៗៗ។

នឹកឃើញកាលពីថ្ងៃរៀបការរបស់លីដេ នាងបានគប់ផ្កាមកឱ្យខ្ញុំ ថែមទាំងទាយទុកផងដែរថា ខ្ញុំនេះនឹងត្រូវរៀបការមុនថ្ងៃខួបកំណើតម្ភៃប្រាំបួនឆ្នាំ។ ដោយសារវាមិនដល់មួយខែទៀតទេ ដល់ពេលដែលពាក្យទំនាយរបស់លីដេ ក្លាយជាអសារឥតការហើយ ខ្ញុំដឹង។

ខ្ញុំមិនដែលជាលើស្នេហាពិតស្អីទេ អាចថា ព្រះដែលកាន់ខាងនាយកដ្ឋានស្នេហា មិនមានចិត្តល្អសាបព្រោះរឿងនេះមកក្នុងជីវិតខ្ញុំ ចំពោះខ្ញុំសូម្បីម្ដងណា។

ខ្ញុំបានបាត់បង់ការចងចាំថា មានប្រុសចំនួនប៉ុន្មាននាក់ដែលមកបង្ហូចចិត្តសុទិដ្ឋិនិយមរបស់ខ្ញុំចំពោះពិភពលោកយើងនេះ។

ធ្លាប់មានពេលមួយដែរ ដែលខ្ញុំគិតថា ខ្ញុំបានរកឃើញមនុស្សល្អ ដែលអាចទាក់ទាញបេះដូងខ្ញុំជាមួយនឹងមន្តតតខ្មោះ ប៉ុន្តែថ្ងៃមួយនោះបានកន្លងផុតទៅ ជាយូរមកហើយ។

«ប្រសិនបើពីរនាក់ហ្នឹងរៀបការនៅកន្លែងនេះ ខ្ញុំនឹងទាយថា នៅជាមួយគ្នាបានមួយសប្ដាហ៍» ខ្ញុំនិយាយយ៉ាងវាហីដាក់ត្រចៀកលីដេហើយងាកទៅទីផ្សេង ខ្ញុំលបន្តមើលនារីភ្លើតភ្លើនដែលស្លៀករ៉ូបសនោះ។

«រៀបការនៅឡាសវេហ្គាស ហើយក្នុងកាស៊ីណូទៀត គឺជាល្បែងទាក់សេដ្ឋី!» លីដេបន្ថែមតពីក្រោយខ្ញុំ។

ឃើញខ្ញុំមិនមាត់ នាងបន្ថែម៖

«តែបងឯង កុំបាច់ធ្វើបាបបេះដូងខ្លួនឯងខ្លាំងពេកដែរ! បណ្ដោយៗខ្លះទៅ!»។

បណ្ដោយស្អី? ខ្ញុំគិតតែមិនមាត់ទេ ដោយយកដៃមកទប់លើសំពត់ខ្លីផ្លេកៗពណ៌ខៀវស្រស់ដែលខ្ញុំកំពុងពាក់។ សំពត់នេះជាអំណោយមួយពីអ្នកឧបត្ថម្ភជាច្រើនរបស់ខ្ញុំ ពួកគេចង់ឱ្យខ្ញុំឆាប់រកបានគូរព្រេង។

នៅពេលដែលខ្ញុំបានចេញប្រកាសនៅលើ IG ថាខ្ញុំកំពុងធ្វើដំណើរទៅ Vegas សម្រាប់ចុងសប្ដាហ៍ ខ្ញុំទទួលសារជាច្រើនពីក្រុមហ៊ុនដែលកំពុងស្វែងរកចំណេញលើប្រជាប្រិយភាពអនឡាញរបស់ខ្ញុំ។ ពួកគេចង់ឱ្យខ្ញុំប្រើប្រេនរបស់ពួកគេ។

ខ្ញុំជាអ្នកមានឥទ្ធិពល.....គួរសមដែរលើបណ្ដាញសង្គម។ ចំនួនអ្នកតាមដាខ្ញុំនៅលើ វេទិកាទាំងអស់គឺរាប់សិបលាននាក់ច្រើនជាងពលរដ្ឋសរុបស្រុកខ្មែរផង។

មនុស្សចម្លែករាប់មិនអស់ ចូលចិត្តតាមដាន និងពិនិត្យមើលគ្រប់រូបភាព វីដេអូ អ្វីៗដែលខ្ញុំបង្ហោះ។ មិនថា ខ្ញុំកំពុងបង្ហាញអំពីពណ៌ក្រែមលាបមាត់ថ្មី ឬខ្ញុំនៅក្នុងផ្ទះបាយនៃភោជនីយដ្ឋានអ៊ីតាលីរបស់ជីដូនមួយខ្ញុំឬដើរ Shopping នៅញូវយ៉ក។ អ្នករាល់គ្នា រមែងមានយោបល់ផ្សេងៗមិនចេះអស់ លើរាល់ការធ្វើសកម្មភាពរបស់ខ្ញុំ។

ម្យ៉ាងដែរ!

«ខ្ញុំចូលចិត្តសំពត់បងឯង!»

លើដេមកតាមទៀត ហើយញញឹម ចង្អុលមកអ្វីដែលខ្ញុំកំពុងស្លៀកពាក់។ ពេលសម្លឹងមើលទៅសំពត់ស្បែកពណ៌ខ្មៅ និងអាវពណ៌ផ្កាឈូករបស់ប្អូន ខ្ញុំបង្ខំឆ្លើយៈ

«ឈុតឯងក៏មើលទៅស្អាតប្លែកលើដេ!»

ប្អូនស្រីរបស់ខ្ញុំ និងខ្ញុំមានពណ៌សក់ទង់ដែងហើយធម្មជាតិដូចគ្នា ប៉ុន្តែនាងកាត់ខ្លី ហើយមានភ្នែកក្រឡង់ៗស្រស់បំព្រង មិនស្រដៀងបន្តិចណាជាមួយភ្នែក sad sad របស់ខ្ញុំទេ។ ខ្ញុំកើតមកមានភ្នែកពណ៌ត្នោតហើយគិតច្រើន ដូចនឹងម៉ាក់។

«បងឯងនិងបងតុនល្មមឈប់ពាក់មុខយក្ខដាក់គ្នាហើយ!»

ខ្ញុំមិនបានឆ្លើយទេ ប៉ុន្តែខ្ញុំនៅចាំពីការឈ្លោះគ្នា ចុងក្រោយរវាងខ្ញុំនិងប៊ុសាំងហ្គពួរ។ ទើបតែកន្លងផុតទៅ ជិតមួយឆ្នាំមុននៅលើចិញ្ចើមផ្លូវនៅកាច់ជ្រុង Fifth Avenue និង 34th Street ក្នុងស្រមោលនៃអគារ Empire State ។

ពេលនោះខ្ញុំកំពុងណាត់ជួបអាមេរិកម្នាក់ឈ្មោះ Logan គេជាប្រុសស្អាតសង្ហា និងជោគជ័យខ្លាំងគួរសម។

ខ្ញុំជឿថា យើងសមគ្នាទាំងគ្រួសារនិងកេរ្តិ៍ឈ្មោះ តែយប់នោះ ហ្សាងជី ហៅប៊ុតុន គេមកញ៉ាំអីនៅទីនោះដែរ។ គេឃើញពួកខ្ញុំ ក៏ធ្វើចរិតមើលតែគេខ្លួនឯងហ្នឹងជាបងប្រុសធំរបស់ខ្ញុំ ហើយស្ដាត់ព្រមានខ្ញុំថា Logan ជាមនុស្សបោក។ ខ្ញុំខឹងហើយបណ្ដេញគេទាំងខឹងស្រក់ទឹកភ្នែក ព្រោះគេប្រហែលជាជឿតាមបងមីកថាខ្ញុំមានក្រយៅប្រុសបោក។

ប៊ុតុនបានអះអាងថា ស្គាល់មនុស្សជុំវិញ Logan ច្បាស់ តែគេបានដើរចេញនៅពេលខ្ញុំសួររកព័ស្តុតាងនិងព័ត៌មានបន្ថែម ឈ្មោះពួកអ្នកដែលគេជឿនិងសាបព្រោះ រឿងអាស្រូវទាំងអស់អំពី Logan ។

គេគ្មានទេ!

ប្រាំមួយខែក្រោយមក គេបានឡើងយន្តហោះទៅរដ្ឋកាលីហ្វ័រញ៉ា ហើយមិនបានត្រលប់ទៅញូវយ៉កសោះ ខ្ញុំបន់ឱ្យតែជាតិនេះលែងបានជួបគេទៅចុះ។

តាំងពីពេលនោះមក loagn ក៏ខឹង និងមិនដែលមករកខ្ញុំវិញទេ។

ខ្ញុំដឹង ការបែកបាក់គ្នានេះក៏មិនមែនបានន័យថា ជាប់ពាក់ព័ន្ធនឹងការចោទប្រកាន់របស់តុនទាំងស្រុងដែរ គឺល្ងាចបន្ទាប់ Logan ចង់ឱ្យពួកយើងរកឱកាសស៊ីជម្រៅស្គាល់ចិត្តគ្នា តែខាងខ្ញុំនៅមិនទាន់បានត្រៀមខ្លួនសម្រាប់ជំហាននេះ ដូច្នេះ logan គិតថា ខ្ញុំជឿតាមប៊ិតុន។

ដកអារម្មណ៍ចេញពីរឿងខឹងៗៗៗ ក៏ក្រឡេកមកវិញ ឃើញការសម្លឹងរបស់ប៊ិតុខ្វាស់មកលើខ្ញុំ។ ភ្នែកពណ៌ខ្មៅលិបតិចៗរបស់គេបិទមកលើផ្ទៃមុខរបស់ខ្ញុំហើយទម្លាក់ឆ្វាចៗមកលើរាងកាយរបស់ខ្ញុំពីលើដល់ក្រោម។

ហើយ.....រេ ...វ៉ាសត្រលប់មកមើលមុខខ្ញុំវិញសារជាថ្មីទៀត ហ៊ានណាស់ប៊ិសាំងហ្គពួរ ។

មើលខ្ញុំមិនមែន?

ខ្ញុំញាក់ចិញ្ចើមសួរដោយគ្មានសំឡេង ធ្វើឱ្យផ្លាស់ទីដើរតម្រង់មកហំៗ។

ខ្ញុំចង់ចេញភ្លាម តែនៅធ្មឹងទៅវិញ។

សាច់ដុំនិងរាងសង្ហាដូចប្រុសអាគាំង គឺ Hot Hot ដូចសព្វដង។ សក់ពណ៌ត្នោតខ្មៅក្រាស់របស់គេកាត់ខ្លីជាងដែលខ្ញុំចាំបាន ប៉ុន្តែនៅតែលេងស្ទីល។

កាត់សក់ម្តង៥០០ដុល្លារបងមីកតែងរអ៊ូពីប៊ិនេះ។

ភាពជាមនុស្សប្រុស រឹងមាំ និងរឹងរូស គ្របដណ្តប់ថ្គាមរបស់គេ ហើយភ្នែកគេតែងតែបែបនេះមើលមកខ្ញុំដូចហ្លួងហែង។

សារភាពក៏បាន ខ្ញុំក៏ធ្លាប់មានចិត្តស្រលាញ់គេនេះមួយភ្លែតដែរអង្កាល់ពីនៅពេលខ្ញុំទើបតែធំមានអាយុ១៧ឬ១៨ឆ្នាំ ភ្លេចហើយ! កាលហ្នឹងគេមានអាយុម្ភៃប្រាំឆ្នាំ ប៉ុន្តែស្នេហាភ្លើងចំបើងហ្នឹងមិនដែលបានបានចាប់ផ្តើមឱ្យពិតប្រាកដទេ។

កាលហ្នឹង មានម្តង ខ្ញុំបានទៅលេងអាផាតមិនដែលគេបានស្នាក់ជាមួយបងប្រុសរបស់ខ្ញុំ។ រសៀលថ្ងៃសៅរ៍នោះ ខ្ញុំសង្ឃឹមថានឹងមានពេលតទល់ជាមួយប៊ិនេះពីរនាក់ស្ងាត់ៗ ហើយខ្ញុំបានជឿជាក់ខ្លួនឯងថា ពួកយើងពិតជាមានអារម្មណ៍ចំពោះគ្នា។

ដឹងអី គេនេះមកបើកទ្វារដោយគ្មានពាក់អាវហើយអញ្ជើញខ្ញុំចូល តែ....ហ៊ឹម ខ្ញុំឃើញស្រីចិនម្នាក់ដើរចេញពីបន្ទប់គេងរបស់គេ ហើយ.....អ្វីយពាក់អាវយឺតប្រុសមួយរបស់គេ។

ខ្ញុំខឹងសឹងចេញផ្សែងនៅពេលនាងនោះ រំអុកហៅគេទៅគេងវិញ។

បងតុនបានប្រាប់នាងនោះថា ខ្ញុំមករកបងម៉ឺកទេ ចាំដល់ខ្ញុំចាកចេញទៅសិនចាំគេទៅរកនាងវិញ។ ខ្ញុំឮកាលណារត់ចេញទាំងអាម៉ាស់។

«នែ៎ បងឯងកំពុងថ្លក់ភ្នែកជាមួយបងតុន!»

លីដេខ្សឹបដាក់ត្រចៀកខ្ញុំ។

សម្ដីរបស់នាងធ្វើឱ្យខ្ញុំដកភ្នែកមកវិញយ៉ាងរហ័សហើយបែរខ្នងធ្វើហី ប្រុងចាកចេញតាមចរិតស្រីស្អាតរបស់ខ្ញុំហើយឆ្លើយយ៉ាងឡូយថូយឡើងថា៖

«ខាងណោះមិនស្រលាញ់ប្រុសចាស់ទេ!»

ឮខ្ញុំនិយាយបែបនេះ បានធ្វើឱ្យប្អូនពៅរបសខ្ញុំសើចខិកៗ។

ខ្ញុំដឹង លីដេចង់បន្ទោសថា ខ្ញុំនេះធ្វើដូចជាខ្លួនឯងមិនចេះចាស់ហើយខាងប្រុសសាំងហ្គាពួរម្នាក់នោះចេះចាស់តែខាងគេ។

ខ្ញុំពោលបង្ហើយទៅកាន់កែវភ្នែកមិចដឹកញីបន្ស៊ីឈ្មោះរេចុះឡើងរបស់ប្អូន៖

«បងទៅផ្ទះវិញហើយ! ហត់!»

«ចង់ដកដង្ហើមបន្ធូរ ក្រោយសម្ពាធព្រោះឃើញប្រុសស្អាត?!»

«សម្ពាធតឹងទ្រូងពេលមានប្អូនរលាម!»

«វាមិនដែល! មុនហ្នឹងមានឃើញបងឯងសម្ពាធផង!»

«បងទៅរកអារីតា!»

ខ្ញុំនិយាយដោះសារ ។ ឯអារីតា នាងជាអនាគតបងថ្លៃរបស់ពួកយើង នាងជាអនាគតភរិយាបងម៉ឺក។

ពីកាលជាងដប់នាទីមុន នាងបានចេញពីកាស៊ីណូ នេះឡើងទៅបន្ទប់ដែលនាងស្នាក់ខាងលើជាមួយបងម៉ឺក។

នាងផ្ដាំថា ពេលហត់ ឬធុញនឹងភាពអ៊ូអរអាចឡើងទៅសម្រាកបណ្ដោះអាសន្នសិនបាន។

បងប្រុសរបស់ខ្ញុំតែងតែមើលថែខ្ញុំ ដូច្នេះខ្ញុំចង់តែនៅក្បែរគាត់ តែគាត់មិនអាចជាបងល្អរហូតទេ គាត់ដល់ពេលធ្វើជាប្ដីល្អហើយ។

អ្វីដែលពិសេសសម្រាប់គាត់ គឺខ្ញុំទទួលយកអារីតានៅពេលពួកគេភ្ជាប់ពាក្យ។ ខ្ញុំបានរៀបចំកន្លែងស្នាក់នៅ មួយលើកាស៊ីណូVegasនេះ ដើម្បីផ្តល់ឱ្យគាត់នូវការសម្រាកពីភាពតានតឹងក្នុងជីវិត ក្នុងនាមជារៀមច្បងគ្រួសារ។

គាត់ឥឡូវរ៉ាប់រងការងារគ្រប់គ្រងផលប័ត្រវិនិយោគនៃមនុស្សអភិជន មន្ត្រីមានតួនាទីធំដុំនៅ Manhattan ឯគូដណ្តឹងរបស់គាត់ឈ្មោះ Arietta អារីតា ជាជនជាតិអ៊ីតាលី រៀនខាងច្បាប់។ ពួកគេពីរនាក់ស័ក្តិសមឥតទាស់ជាមួយជីវិតស៊ីវិល័យនៅក្រុងមួយនេះ។ យប់នេះ ជាការជប់លៀងមួយអបអរការងារ Project ថ្មីរវាងពួកគេដែរ។ អារីតានិងបងមីក! ស្នេហាក៏ស្អិត លុយក៏រកបាន! ហ៊ឹម!

មុនពេលដែលខ្ញុំអាចឈានចេញឆ្ងាយពីទីនេះបាន ប៊ិសាំងហ្គពួរប្រកាសដោយសំឡេងស្រាលៗ៖

«ហេ៎ ទាំងអស់គ្នា យើងដល់ពេល រំឭកដល់គូស្នេហ៍ដែលជាម្ចាស់កម្មវិធីហើយ! ពីរនាក់ហ្នឹងទៅសំងំនៅឯណាបាត់ហើយ មានអ្នកណាទាន់ដែរ?»

ជាសំឡេងមួយដែលបេះដូងខ្ញុំ ធ្លាប់លបលួចនឹកស្រមៃមុនពេលខ្ញុំរកឃើញស្រីចិនក្នុងបន្ទប់គេ។

តាំងពីពេលនោះមក ខ្ញុំបានធ្វើអ្វីគ្រប់យ៉ាងតាមដែលអាចធ្វើទៅបាន ដើម្បីចៀសវាងការឮតុនហានិយាយ។

មនុស្សចាប់ផ្តើមហ៊ោព្រោះថាយើងក្រឡេកមើលឃើញ បងប្រុសខ្ញុំកាន់ដៃគូដណ្តឹងគាត់យ៉ាងតឹងហើយបណ្តើរគ្នាចេញមកបង្អួតពួកយើង។

បងមីកញញឹមដាក់លីដេ នៅពេលនាងផ្អៀងស្មាផ្អែកប្តីរបស់នាងក្បែរៗគ្នា។

ទីបំផុត ខ្ញុំងាកមកវាក់នឹងប៊ិនតុន ផ្តោតភ្នែកលើខ្ញុំ។ ភ្នែកយើងប៉ះគ្នា.....

វាជាចរន្តឆក់ដ៏ខ្លាំង ក្នុងរបៀបដែលខ្ញុំមិនបានរំពឹងទុកមកទេ ដូច្នេះខ្ញុំមិនអាចធ្វើពើជាគ្មានសម្ពាធ ហើយទម្លាក់ការសម្លឹងមកក្រោមវិញភ្លាមៗ។

ការពិតរាងកាយរបស់ខ្ញុំកំពុងឆេះ សូម្បីសម្លឹងគ្នាឆ្ងាយកម្រិតនេះ។ សំណាងដែរ គេនៅឆ្ងាយមិនឮស្នូរដង្ហើមខ្ញុំ។

....តែ....អាចខ្ញុំគិតខុស....ព្រោះពេលខ្ញុំងើបមុខមកវិញ ភ្នែកប៊ិននេះ សម្លឹងចុះមកក និងទ្រូងខ្ញុំ។

ស្អី?

ខ្ញុំលេបសម្ពាតភាពគាំងៗក្នុងបំពង់ក។

ស្នាមញញឹមស្រពាប់ស្រពោនផុសដោយមិនលាក់លៀមលើបបូរមាត់សង្ហារបស់គេ។

គេនិយាយតែគេ ឯភ្នែកថ្លក់ជាមួយខ្ញុំ៖

«ផ្អែមណាស អាមីកនិងអារីតា! ផ្អែមខ្លាំង!»

ពាក្យពីរម៉ាត់ចុងក្រោយនេះ ធ្វើឱ្យខ្ញុំស្រាលដៃជើង។ គេនោះ មានសំឡេងព្រាន! ខ្ញុំគិត! ភ្នែកគេរឹតតែព្រាន។ គេមិនដឹងជាសាកស្រីអាស៊ី និងអឺរ៉ុបអស់ប៉ុន្មានមកហើយទេ។

បងប្រុសរបស់ខ្ញុំធ្លាប់អួតថា ស្រីណាក៏លង់តុនដែរ តែតុនទេ មិនងាយលង់អ្នកណា។

សម្ដីបងខ្ញុំ ធ្វើបាបចិត្តប្អូនខ្លាំង តែគាត់មិនដឹង។

ប៊ិនោះ ដឹងអង្គាល់បានឈប់ថ្លក់ភ្នែកជាមួយខ្ញុំទេ គេងក់ក្បាលដោយមើលមុខខ្ញុំជានិច្ចទាំងដែលសម្ដីគេយ៉ាងផ្ដោតការយកចិត្តទុកដាក់លើបងមីកនិងអារីតាឯណោះ។

«ខ្ញុំរំភើបចិត្តនិងបារម្ភនៅពេលដែល មីកប្រាប់ខ្ញុំទាំងស្រវឹងថា គេចេះលង់ស្នេហ៍ហើយ! ក្រោយមក ខ្ញុំគិតថាសមហេតុផល ព្រោះអ្នកនោះជាមនុស្សគួរឱ្យស្រលាញ់ដូចអារីតា!»

សំណើចគេអណ្ដែតតាមខ្យល់ ហើយប៉ើងចោលចេញពីអ្នករាល់គ្នា មកគ្របកម្ដៅបេះដូងរងារបស់ខ្ញុំ។

មិនយូរផងទេ ការសើចរបស់ប៊ិតុនបានរសាត់ទៅបាត់ហើយគេនិយាយទៀត៖

«អារីតា ស័ក្ដិសមណាស់ ព្រោះនាងបានជួយឱ្យមីកមើលឃើញភាពស្រស់ស្អាតនៃពិភពលោកតាមរយៈកែវភ្នែកថ្មីពេញដោយភាព.....ផ្អែមល្ហែម! ខ្ញុំស្គាល់អាមីករហូតមកហើយ ដែលខ្ញុំអាចនិយាយដោយទំនុកចិត្តថា ខ្ញុំមិនដែលឃើញគេសប្បាយចិត្តឯណាដូចឥឡូវនេះទេ!»

បងប្រុសរបស់ខ្ញុំលើកដៃហើយនិយាយកក្អឹកថា៖

«បានហើយហ្សាងជី!»

គ្រប់គ្នាសើចទៀតហើយ ប៉ុន្តែខ្ញុំ.....ធ្វើម៉េចសម? ធ្វើដូចមិនឮទៅចុះ!»

តាមពិតពេលនេះ ម៉ោងនេះ បេះដូងខ្ញុំស្រឡាំងកាំងដែលប៊ិតុន ចេះមានទស្សនាទានស្នេហាអីនឹងគេដែរ?

ស្មានរហូតមកថាមនុស្សធន់គេ មិនដែលស្គាល់ឬខ្វល់ទេពីជម្រៅនៃសេចក្តីស្រលាញ់លើលោក។ គេចេះតែណាត់ស្រីទៅបន្ទប់.....តែប៉ុណ្ណឹង។

«សុន្ទរកថាពេលនេះ ជាសារមួយសម្រាប់មនុស្សដែលឯកោៗ ឱ្យយល់ៗ!»។

តុននិយាយនិងសប្បាយសើចខណៈខ្ញុំបានប្រមូលមកទុកគិតតែម្នាក់ឯង ថាគេនេះដូចជាថាឱ្យខ្ញុំ?

មិនដឹងធ្វើម៉េច ខ្ញុំមានតែធ្វើពើជាសម្លឹងមើលអារីតានិងបងមីក។

បងខ្ញុំងក់ក្បាលយឺតដោយងាកសម្លឹងគូដណ្តឹងរបស់គាត់ហើយនិយាយឡើងស្រាលៗ៖

«អារីតាជាសេចក្តីស្រលាញ់ពិតដែលខ្ញុំពីមុនមិនដែលជឿថាមាន ក៏ជាអត្ថន័យមួយធំ នៃជីវិតនៅសល់របស់ខ្ញុំ»។

តុនឮហើយគេញញឹម លើកកែវឡើងលើអាកាសប្រកាសឡើងបន្ត៖

«តស់! ឆៀរមួយសម្រាប់អារីតានិងមីក»

គ្រប់គ្នាលើកកែវ ខ្ញុំវិញក៏ធ្វើតាម និងជូនពរបងប្រុសរបស់ខ្ញុំជាមួយអារីតា ឱ្យជួបតែសេចក្តីសុខគ្រប់ប្រការនៅក្នុងពិភពលោកនេះ។

គាត់កំពុងរង់ចាំកែវរបស់គាត់នៅក្នុងដៃរបស់គាត់។

«ទៅ Dominick និង Arietta»។

## ជំពូកទី ២

## ស្រីស្រអែមមុខរឹង

ខ្ញុំផ្អៀងខ្នងមកផ្អែកទល់នឹងទ្វារបន្ទប់សណ្ឋាគារ ហើយដកដង្ហើមវែងៗ ប៉ុន្តែវាមិនចេះពេញសួតទេ នៅតែដង្ហក់ៗព្រោះមានអារម្មណ៍ថា ត្រូវដាល់ចំកណ្ដាលទ្រូងព្រោះវត្តមានស្រីខ្មែរម្នាក់នោះ។

ម៉ាលីយ៉ា!

អារម្មណ៍នោះបានកើតឡើងនៅពេលដែលខ្ញុំបានឃើញនាងជាមួយសំពត់ផិតធើយស្អាតឥតទាស់ នៅជាន់កាស៊ីណូខាងក្រោម។ លោកព្រះ! នាងស្អាតជាងរូបដែលខ្ញុំដេកឱបលើទូរសព្ទ។

ខ្ញុំលបមើលគេ ជារៀងរាល់ថ្ងៃក្នុងទម្រង់រូបភាពក្ដី វីដេអូក្ដី។ គេប្រហែលមិនដឹងទេថា មិត្តម្នាក់របស់បងគេ តែងតែតាមដានគណនីបណ្ដាញសង្គមរបស់គេទាំងអស់ក្រោមឈ្មោះក្លែងក្លាយ។

ដឹងទេ? នាងគឺជាមនុស្សលើអនឡាញតែម្នាក់គត់ដែលខ្ញុំតាមដានមិនចេះហត់។

ការគោះទ្វារខ្លាំងៗមួយបាននាំខ្ញុំមួយជំហានឆ្ពោះទៅមុខ លាក់បាំងអារម្មណ៍«ស្នេហ៍»។

ខ្ញុំយកដៃជូតមុខប្រឹងប្រែងបង្ហាញចរិត ស្ងប់ស្ងាត់ចុះទៅរកកម្មវិធីខាងក្រោម។ នឹកឃើញរឿងចាស់ៗ ឱ្យតែគ្រួសារអាមីកមកលេងអាមេរិក ហើយយើងអង្គុយញ៉ាំអាហារជុំគ្នា ខ្ញុំតែងនៅទល់មុខមនុស្សស្រីអាស៊ី ដែលទាក់ទាញបំផុតនៅលើភពផែនដី។

គ្រាអស់ទាំងនោះ ខ្ញុំរមែងតែងតែពិបាកដូចទ្រូងសណ្ដូនថ្មនៅគ្រប់វគ្គ ហើយទីបំផុតនៅពេលដែលគេសម្លឹងមើលចំខ្ញុំនៅពាក់កណ្ដាលផ្លូវដែលយើងងាកចុះឡើង ខ្ញុំស្ទើរតែញាក់ដៃដូចចុះចាញ់សង្គ្រាម។

ទោះបីជានាងច្រម៉ក់និងខ្ញុំ រមែងតែងមានការឈ្លោះប្រកែកគ្នា តែប៉ុន្មានឆ្នាំមកនេះ មិនដែលមានពេលមួយថ្ងៃណាកន្លងផុតទៅដោយខ្ញុំមិនគិតពីនាងនោះទេ។

ខ្ញុំបង្វិលខ្លួនហើយបើកទ្វារដោយដកដង្ហើមធូរស្រាលពេលឃើញ អាមីក។

សម្លាញ់ខ្ញុំសើចសឹងធំដល់គុម្ពពីត្រចៀកព្រោះមានក្ដីសុខ។